**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

SECURITIES AND EXCHANGE REGULATOR OF CAMBODIA

**និយ័តករមូលបត្រកម្ពុជា**

លេខ: ៨៣ / ២៥ ន.ម.ក. / ស.ជ.ណ.

# សេចក្ដីជូនដំណឹង
# ស្ដីពីការអនុម័តដាក់ឱ្យប្រើប្រាស់
# ប្រកាសស្ដីពីការផ្ដល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មទ្រព្យឌីជីថល

**និយ័តករមូលបត្រកម្ពុជា** ( ន.ម.ក. ) មានកិត្តិយសសូមជម្រាបជូនដំណឹងដល់សាធារណជនទាំងអស់ជ្រាបថា៖ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** បានអនុម័តដាក់ឱ្យប្រើប្រាស់នូវប្រកាសលេខ ០៩៣ អ.ស.ហ.ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៥ ស្ដីពីការផ្ដល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មទ្រព្យឌីជីថល។ ដូចនេះ បុគ្គលដែលទទួលបានជោគជ័យក្នុងការសាកល្បងបច្ចេកវិទ្យាព័ត៌មាន គំរូអាជីវកម្ម ផលិតផល ឬសេវាកម្មដែលពាក់ព័ន្ធនឹងទ្រព្យឌីជីថលក្នុងបរិស្ថានសាកល្បងបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យមូលបត្រ អាចដាក់ពាក្យស្នើសុំអាជ្ញាបណ្ណធ្វើអាជីវកម្មទ្រព្យឌីជីថលមក ន.ម.ក. ស្របតាមប្រកាសនេះ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកនាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ តាមរយៈទូរសព្ទលេខ ០២៣ ៨៨៥ ៦១១ ឬទូរសព្ទមន្ត្រីទទួលបន្ទុកលេខ ០៩៦ ៣២២ ៣៣៣៩ ឬអ៊ីមែល intermediaries@serc.gov.kh។

សេចក្ដីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់ជ្រាបជាព័ត៌មាន។

ថ្ងៃ ពុធ ១២កើត ខែ បុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ គ.ស.២០២៥

**និយ័តករមូលបត្រកម្ពុជា**

សូមទាញយកប្រកាសនេះ
តាមរយៈ QR Code ខាងក្រោម៖

អាសយដ្ឋាន : អគារ១៦៨F ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ កម្ពុជា ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Address : Building 168F, Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Cambodia
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@serc.gov.kh Website: www.serc.gov.kh